# សេចក្តីថ្លែងការណ៍រួម
# ស្តីពី
# សង្គមស៊ីវិលជំរុញឲ្យមានដំណោះស្រាយជម្លោះព្រំដែន កម្ពុជា ថៃ ដោយសន្តិវិធី

ភ្នំពេញ, ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១

យើងខ្ញុំទាំងអស់គ្នា ជាតំណាងឲ្យសម្ព័ន្ធសមាគម អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា សូមសំដែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការប៉ះទង្គិចដោយអាវុធរវាងកងទ័ពកម្ពុជា និងកងទ័ពថៃ នៅតាមព្រំដែនតំបន់ប្រាសាទព្រះវិហារ កាលពីពេលថ្មីៗនេះ ដែលបានធ្វើឲ្យប៉ះពាល់ដល់អាយុជីវិត ការរស់នៅ និងសន្តិសុខរបស់ប្រជាពលរដ្ឋស៊ីវិល នៅតាមតំបន់នោះ យ៉ាងធ្ងន់ធ្ងរ។

សម្ព័ន្ធសមាគម អង្គការមិនមែនរដ្ឋាភិបាល បានតាមដានដោយយកចិត្តទុកដាក់ទៅលើបញ្ហាជម្លោះព្រំដែនរវាងប្រទេសកម្ពុជា និងប្រទេសថៃ ទាំងសកម្មភាពទំនាស់ និងទាំងសកម្មភាពនៃការដោះស្រាយទំនាស់នេះ នាពេលកន្លងមករហូតដល់ពេលនេះ។ យើងខ្ញុំទាំងអស់គ្នាបានមើលឃើញថា ចាប់តាំងពីមានការផ្ទុះអាវុធលើកទី១ នៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ មក ភាគីទាំងពីរ គឺភាគីកម្ពុជា និងភាគីថៃ បានខិតខំដោះស្រាយជម្លោះតាមរយៈការចរចារទ្វេរភាគី ក៏ប៉ុន្តែការចរចារទាំងនោះមិនដែលបានទទួលលទ្ធផលគាប់ប្រសើរទេ។ ផ្ទុយទៅវិញការចរចារបានគ្រាន់តែធ្វើឲ្យសភាពការណ៍សន្តិសុខនៅតាមព្រំដែនខាងលើដុនដាបទៅៗ រហូតដល់មានការផ្ទុះអាវុធជាបន្តបន្ទាប់ ជាពិសេស គឺការផ្ទុះអាវុធធុនធ្ងន់ នៅក្នុងអំឡុងដើមខែកុម្ភៈ ឆ្នាំ២០១១ ថ្មីៗនេះ។

យើងខ្ញុំទាំងអស់គ្នាយល់ឃើញថា ការដោះស្រាយជម្លោះនេះ តាមរយៈការប្រើប្រាស់យន្តការថ្នាក់តំបន់ (សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថា "អាស៊ាន") និងយន្តការអន្តរជាតិ (ក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ) គឺជាការចាំបាច់ ដែលរាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើដោយមិនអាចខានបាន ពីព្រោះថា ការចរចារទ្វេរភាគីមិនបានទទួលលទ្ធផលជាផ្លែផ្កា ដោយសារតែភាគីថៃមិនបានគោរពពេញលេញតាមកិច្ចព្រមព្រៀង ដែលជាលទ្ធផលនៃការចរចារនោះទេ។

ទាក់ទិននឹងស្ថានភាពបច្ចុប្បន្ននេះ យើងខ្ញុំសូមស្នើសុំឲ្យប្រទេសទាំងពីរបញ្ឈប់ការបាញ់គ្នាជាបន្ទាន់ ក៏ដូចជា ជៀសវាងនូវការប្រទុស្តរាយខាងយោធាជាថ្មីម្តងទៀត ហើយខិតខំធ្វើការដោះស្រាយជម្លោះដោយការចរចារតាមពហុភាគីវិញ។

ទន្ទឹមនឹងនេះដែរ យើងខ្ញុំក៏សូមសំដែងនូវការអបអរសាទរ និងគាំទ្រចំពោះចំណាត់ការរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលបានយកចិត្តទុកដាក់ក្នុងការដោះស្រាយជម្លោះ តាមរយៈការប្តឹងទៅក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ។

ដោយសារតែការបរាជ័យ នៃការដោះស្រាយតាមរយៈការចរចារជាទ្វេរភាគីជាមួយនឹងភាគីថៃ យើងខ្ញុំសូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ឲ្យបញ្ឈប់យន្តការនេះដោយជំនួសមកវិញនូវការដោះស្រាយជម្លោះនេះដោយពហុភាគី ដោយមានការចូលរួមពីស្ថាប័នថ្នាក់តំបន់ និងស្ថាប័ន

អន្តរជាតិ។ ដូចគ្នាដែរ យើងខ្ញុំក៏សូមអំពាវនាវដល់អង្គការសហប្រជាជាតិ និង ប្រទេសហត្ថលេខី នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស មេត្តាយកចិត្តទុកដាក់ដោះស្រាយបញ្ហាជម្លោះនេះប្រកបដោយសន្តិវិធី និងឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

ខាងក្រោមនេះ គឺជាឈ្មោះសម្ព័ន្ធសមាគម អង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ:

| ឈ្មោះ | តួនាទី | លេខទូរស័ព្ទ | អង្គការ/សមាគម |
|---|---|---|---|
| លោក ធន សារាយ | ប្រធានសម្របសម្រួល | ០១៦ ៩៤០ ០៩៤ | គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) |
| លោក គល់ បញ្ញា | នាយកប្រតិបត្តិ | ០១២ ៩៤២ ០១៩ | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) |
| លោក ឈិត សំអាត | នាយកប្រតិបត្តិ | ០១២ ៩២៨ ៥៨៥ | វេទិកា នៃអង្គការមិនមែនរដ្ឋាភិបាលស្តីពី កម្ពុជា (NGO Forum) |
| លោកស្រី ធិតា ឃឹះ | អគ្គលេខាធិការ | ០១២ ៨០២ ៣៨៩ | គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ (CPWP) |
| លោក លន់ បូរិទ្ធី | នាយកប្រតិបត្តិ | ០១២៨៣៨ ៩៦៩ | គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) |
| លោកស្រី ដេត ចរិយា | នាយិការប្រតិបត្តិ | ០១២ ៨០២ ៩៦០ | អង្គការស្តារកម្ពុជា (STAR Kampuchea) |
| លោក ឈៀង សុខា | នាយកប្រតិបត្តិ | ០១២ ៣៦០ ៩៦៩ | កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP) |
| លោក ប៉ែន សុមុនី | នាយកប្រតិបត្តិ | ០១២ ៧០៨ ០៩៣ | អង្គការអ្នកស្ម័គ្រចិត្ត ដើម្បីសង្គម (CVS) |